ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ
# សហគមន៍ អូរក្រសារ
## សម្រាប់រយៈពេល ៣ ឆ្នាំ
(ខែកក្កដា ឆ្នាំ២០១៩ - កក្កដា ឆ្នាំ២០២២)

| | |
|---|---|
| សហគមន៍នេសាទ | ៖ អូរក្រសារ |
| ភូមិ | ៖ អូរក្រសារ |
| សង្កាត់ | ៖ អូរក្រសារ |
| ក្រុង | ៖ កែប |
| ខេត្ត | ៖ កែប |

ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៩

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ៤

**២.អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម** ........ ៤

ក.ប្រជាពលរដ្ឋ ........ ៤

ខ.មុខរបរ ........ ៥

**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ៥

ក.ទីតាំង ........ ៥

ខ.ដែននេសាទ ........ ៥

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៦

ឃ.ធនធានជលផល ........ ៦

ឃ.១.ប្រភេទត្រីសមុទ្រ ........ ៦

ឃ.២.ប្រភេទវារីសត្វសមុទ្រ ........ ៦

ឃ.៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ ........ ៧

**៤.ការធ្វើនេសាទ** ........ ៧

ក.អ្នកនេសាទ ........ ៧

ខ.ឧបករណ៍នេសាទ ........ ៧

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៨

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៨

ក.ទស្សនៈវិស័យ ........ ៨

ខ.គោលបំណង ........ ៨

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៩

គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៩

គ.២.ផែនការចុះល្បាត ........ ៩

គ.៣.ផែនការកែលំអរដែននេសាទ ........ ១០

គ.៤.ផែនការរៀបចំកន្លែងអភិរក្ស ........ ១១

គ.៥.ផែនការគ្រប់គ្រងព្រៃកោងកាង ........ ១២

គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១២

គ.៧.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ ........ ១៣

គ.៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ១៣

គ.៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ១៤

គ.១០.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ..............................១៥
គ.១១.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ..............................១៥
ឃ.យុទ្ធសាស្ត្រ..............................១៥
**៦.ឧបសម្ពន្ធ**
ឧបសម្ព័ន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ឆ្នាំ២០១៩-២០២២

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូរក្រសារ

## ១- ស្ថានភាពទូទៅ

នៅឆ្នាំ២០០០រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឱ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការដែលជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាពនិងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍និងធ្វើឱ្យធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ កន្លងមកភូមិអូរក្រសារ ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានទទួលការគាំទ្រថវិកាពីរដ្ឋបាលជលផល និងមានកិច្ចសហការពីអាជ្ញាធរដែនដី។ ដូចនេះសហគមន៍នេសាទអូរក្រសារ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៦ខែមិថុនាឆ្នាំ២០០៥ ព្រមទាំងត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី០៧ ខែឧសភាឆ្នាំ២០១៣ ហើយបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី១ ដែលបានអនុវត្តចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ ហើយលើកទី២បានធ្វើបច្ចុប្បន្នភាពដែលនឹងអនុវត្តចាប់ពីខែកក្កដា ឆ្នាំ២០១៩ ដល់ ខែកក្កដា ឆ្នាំ២០២២។

គណៈកម្មការសហគមន៍នេសាទ ត្រូវបានបោះឆ្នោតរហូតមកដល់ពេលបច្ចុប្បន្នមានសមាជិកសហគមន៍សរុបចំនួន២៣៦នាក់ ក្នុងនោះស្ត្រីចំនួន១០៧នាក់ ហើយគណៈកម្មការសហគមន៍នេសាទមានចំនួន១១នាក់ ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ។ ទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទ បានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំបណ្តាញការងារ ទស្សនៈកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ។

ដូច្នេះ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទអូរក្រសារ បានរៀបចំសកម្មភាពសំខាន់ៗ និងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងអភិរក្សសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយនិរន្តរភាពនិងសមធម៌។

## ២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ពេលបច្ចុប្បន្ន នៅសង្កាត់អូរក្រសារមានពីរភូមិគឺភូមិអូរក្រសារនិងភូមិដំណាក់ចំបក់ក្នុងសហគមន៍នេសាទអូរក្រសារពាក់ព័ន្ធតែមួយភូមិគឺ ភូមិអូរក្រសារដែលមានប្រជាពលរដ្ឋសរុបចំនួន៩៦៧គ្រួសារ ក្នុងនោះស្ត្រីដែលជាមេគ្រួសារមានចំនួន២៥៧គ្រួសារ ហើយមានមនុស្សសរុបចំនួន៤១៣៩នាក់ ក្នុងនោះស្ត្រីមានចំនួន២១២១នាក់។

សហគមន៍នេសាទអូរក្រសារស្ថានភាពដូចជា៖

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងសហគមន៍អូរក្រសារបានបង្ហាញថា នៅភូមិអូរក្រសារមានគ្រួសារក្រីក្រ-១ចំនួន៣៩គ្រួសារ ក្នុងនោះស្ត្រីមានចំនួន២១គ្រួសារនិងគ្រួសារក្រីក្រ-២មានចំនួន៥៩គ្រួសារ ក្នុងនោះស្ត្រីមានចំនួន៣៤គ្រួសារ ដែលសរុបគ្រួសារក្រីក្រ-១និងក្រីក្រ-២មានចំនួន៩៨គ្រួសារ ក្នុងនោះស្ត្រីចំនួន៥៥គ្រួសារ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន២៥៧នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន២៧នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានចំនួន០៨នាក់ ក្នុងនោះស្ត្រីមានចំនួន០៣នាក់

- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៩៧នាក់ ក្នុងនោះស្ត្រីមានចំនួន៦២នាក់
- ចំនួនអ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន០៩នាក់ ក្នុងនោះស្ត្រីមានចំនួន០៥នាក់
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាសង្កាត់ នៅក្នុងសហគមន៍នេសាទអូរក្រសារបានបង្ហាញថា ២៧នាក់ដែលមិនចេះអក្សរ ក្នុងនោះស្ត្រីមានចំនួន១៨នាក់។

**ខ.មុខរបរ**

តាមរបាយការណ៍ និងឯកសារព័ត៌មានរបស់សង្កាត់ឆ្នាំ២០១៩បានបញ្ជាក់ថា ភូមិអូរក្រសារដែលមានប្រជាពលរដ្ឋសរុបចំនួន៩៦៧គ្រួសារ ក្នុងនោះស្ត្រីដែលជាមេគ្រួសារមានចំនួន២៥៧គ្រួសារ ហើយមានមនុស្សសរុបចំនួន៤១៣៩នាក់ក្នុងនោះស្ត្រីចំនួន២១២១នាក់ ហើយប្រជាជនក្នុងភូមិនេះភាគច្រើនពឹងផ្អែកលើការនេសាទនិងធ្វើស្រែ។ ការជួយគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទពីដៃគូអភិវឌ្ឍន៍ជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជួយពង្រីកមុខរបរប្រចាំថ្ងៃដល់ប្រជានេសាទនៅក្នុងសហគមន៍នេះ ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផលនិងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វនិងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទនេះ ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិតនិងមុខរបរសំខាន់ៗរួមមាន៖

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | កំណត់ចំណាំ |
|---|---|---|---|
| ១ | អ្នកមានមុខរបរធ្វើនេសាទ | ២៣៦ | |
| ២ | អ្នកធ្វើស្រែ និងអ្នកចិញ្ចឹមសត្វ | ១៦០ | ទំហំដី ៥៨,៦ហិកតា និង៤៥អា |
| ៣ | អ្នកដាំបន្លែ | ១០ | ទំហំដី០,៣ |
| ៤ | អ្នកលក់ដូរ | ៣០ | |
| ៥ | អ្នកកែច្នៃត្រី | ០១ | |

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

**ក.ទីតាំង**

សហគមន៍នេសាទអូរក្រសារ មានទីតាំងស្ថិតក្នុងភូមិអូរក្រសារដែលជាដែននេសាទសាធារណៈរបស់រដ្ឋជាដែននេសាទសមុទ្រដែលស្ថិតក្នុងសង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប។ សហគមន៍នេសាទអូរក្រសារត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣។

ដូចនេះ សហគមន៍នេសាទអូរក្រសារមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងជាប់នឹងស្រែអំបិល
- ខាងត្បូងជាប់នឹងផ្ទៃទឹកសមុទ្រ
- ខាងកើតជាប់នឹងសហគមន៍នេសាទកំពង់ត្រឡាច
- ខាងលិចជាប់នឹងសហគមន៍នេសាទកំពង់សាមគ្គី។

**ខ.ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទអូរក្រសារ មានវិសាលភាពនៅលើដែននេសាទសមុទ្រដែលមានកន្លែងនេសាទទំហំ៤៤៦ ហិកតា ហើយមានដែននេសាទតំបន់ឆ្នេរ ព្រៃកោងកាង និងព្រៃកដូចជា៖

| ល.រ | ឈ្មោះព្រៃក | ទំហំជាហិកតា | ការនេសាទ |
|---|---|---|---|
| ១ | ព្រៃកក្តប | ៧ | ពេញមួយឆ្នាំ |
| ២ | ព្រៃកអូរក្រសារ | ៩ | ពេញមួយឆ្នាំ |
| ៣ | ព្រៃកជីកថ្មី | ៣ | ពេញមួយឆ្នាំ |
| ៤ | តំបន់ព្រៃកោងកាង | ៤៦,៤១ | |

កន្លែងនេសាទសហគមន៍អូរក្រសារ បានផ្តល់នូវលក្ខណៈងាយស្រួលដល់ការរស់នៅរបស់សហគមន៍មូលដ្ឋាន និងការធ្វើអាជីវកម្មនេសាទសមុទ្ររបស់អ្នកនេសាទខាងក្នុងសហគមន៍ក៏ដូចជាអ្នកមកពីខាងក្រៅសហគមន៍ ជាពិសេសកន្លែងនេសាទសហគមន៍មានអំណោយផលល្អដល់ការរស់នៅរបស់ពពួកវារីសត្វ រុក្ខជាតិ ជាពិសេសជាចំណី ជម្រកពងកូនរបស់មច្ឆា សត្វស្លាបនិងសត្វល្មូនគ្រប់ប្រភេទ។ ម្យ៉ាងទៀតកន្លែងនេសាទសហគមន៍អូរក្រសារ ជាក់ស្តែងបានភ្ជាប់ជាមួយសមុទ្រ ហើយទឹកសមុទ្រមានលក្ខណៈជោរនិងនាចដែលបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទអូរក្រសារ។

ផ្ទៃដែននេសាទរបស់សហគមន៍នេសាទអូរក្រសារមានទំហំសរុបចំនួន៤៤៦ហិកតា ក្នុងនោះមានកន្លែងអភិរក្សកូនក្តាមថ្មមានទំហំប្រហែល៥០ហិកតា តំបន់ព្រៃកោងកាងមានទំហំប្រហែល៤៦,៤១ហិកតា និងកន្លែងនេសាទផ្សេងទៀតមានទំហំប្រហែល៣៤៩,៥៩ហិកតា ។

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍នេសាទអូរក្រសារបានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០២កន្លែង ដែលមានទំហំប្រហែល៩៦,៤១ហិកតា ក្នុងនោះមានកន្លែងអភិរក្សកូនក្តាមថ្មមានទំហំប្រហែល៥០ហិកតា តំបន់អភិរក្សព្រៃកោងកាងមានទំហំប្រហែល៤៦,៤១ហិកតា។ ដូចនេះផងដែរ កន្លែងអភិរក្សត្រូវបានធ្វើការគ្រប់គ្រងដោយសហគមន៍នេសាទកន្លែងអភិរក្សទាំងនេះមានដូចខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហត | ការអភិរក្ស |
|---|---|---|---|
| ១ | កន្លែងអភិរក្សកូនក្តាមថ្ម | ៥០ | ការអភិរក្សធនធានជលផល |
| ២ | តំបន់អភិរក្សព្រៃកោងកាង | ៤៦,៤១ | ការអភិរក្សធនធានជលផល |

**ឃ.ធនធានជលផល**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍អូរក្រសារបានឱ្យដឹងថាពេលបច្ចុប្បន្ន ធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារនិងសមាជិកសហគមន៍ធនធានជលផលក្នុងសហគមន៍នេសាទអូរក្រសារមានដូចជា៖

ឃ.១.ប្រភេទត្រីសមុទ្រ:

ក្នុងសហគមន៍នេសាទអូរក្រសារមានប្រភេទត្រីដូចជា៖ ត្រីឆ្កង់ ត្រីក្បក ត្រីប្រកុង ត្រីអាំងកីយ ត្រីចង្កោមប ត្រីដំឡូង ត្រីឆ្មាធូ ត្រីក្តចិន ត្រីស្លុងក្រហម ត្រីផ្ទោង ត្រីក្រសក់ ត្រីឆ្លាម ត្រីកាវ៉ាវ ត្រីប្រម៉ា ត្រីកិ ត្រីកន្ទង ត្រីកាម៉ុង ត្រីក្បាលឡាន ត្រីអណ្តែងប៉ុយ ត្រីកន្លាំង ត្រីកន្ទុយរឹង ត្រីកាបាស ត្រីបបែល ត្រីឆ្លាត ត្រីក្អុក ត្រីបាលង្គ ត្រីកាឡាំង ត្រីអង្រែ ត្រីគូនត្រីសេក ត្រីតក់កែ ត្រីផ្ទក់សមុទ្រ ត្រីសេះ។ល។

ឃ.២.ប្រភេទវារីសត្វសមុទ្រ:

ក្នុងសហគមន៍នេសាទ មានប្រភេទវារីសត្វដូចជា៖ បង្កង បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹក គ្រែងឈាម ងាវភក់ ហូល ងាវស បង្កងប៉ាក អណ្តើក កន្ទាយ បាលង្គ័កាស កញ្ច អន្ទង់ ខ្ចឹង។ល។

ឃ.៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ

ក្នុងសហគមន៍នេសាទអូរក្រសារ មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ផ្កាថ្ម ស្មៅសមុទ្រ និង តំបន់ព្រៃកោកាងមានដូចជា៖ ព្រៃកោងកាងក្រញឹម អម្ពូ អម្ពា ក្របាញ់ញី ក្របាញ់ឈ្មោល ប៊ីង ប្រសាក ដើមបើស ឈើជ័រ ដើមក្តាយ អញ្ចរ ដើមឡេវឡាវ ដើមដូងទឹក។ល។

**៤-ការធ្វើនេសាទ**

តាមការសិក្សានិងប្រមូលទិន្នន័យពីក្រុមប្រឹក្សាសង្កាត់ ភូមិ និងសហគមន៍អូរក្រសារបានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍អូរក្រសារមានដូចខាងក្រោម៖

**៤.ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២៣៦នាក់ ក្នុងនោះស្ត្រីមានចំនួន១៣៧នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន១០៥នាក់ ក្នុងនោះស្ត្រីមានចំនួន ៧៦នាក់ ។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍មានប្រហែល ៣៥គ្រួសារ ក្នុង១ឆ្នាំ។

**៤.ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | ចំនួនគ្រួសារ | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | មងត្រី | ម៉ែត្រ | ១គ្រួសារ=៣-៤ដៃ ១ដៃ=៥០ម | ៥០ | ខែ ០៥ ដល់ ខែ ១២ |
| ២ | មងក្តាម | ម៉ែត្រ | ១គ្រួសារ=១០០០ម | ០២ | ពេញមួយឆ្នាំ |
| ៣ | លបក្តាម | លប | ០,២មx០,៤មx១,៥ម | ០២ | ពេញមួយឆ្នាំ |
| ៤ | ឈិបរុញដោយដៃ | គ្រឿង | ៥ម ទៅ៦ម | ១០ | ពេញមួយឆ្នាំ |
| ៥ | សន្ទូចរនង | ផ្លែ | ១០០/គ្រួសារ | ៣០ | ខែ ០៥ ដល់ ខែ ១២ |
| ៦ | វាវគ្រែងឈាម ងាវភក់ និងលូកក្តាម | នាក់ | | ៧០ | ខែ ០៥ ដល់ ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ៨៥ | ៥០០-៧០០ | ៦ ដល់ ១៣ |
| ទូកចែវ | ៥០ | ៧០-១០០ | |

ឧបករណ៍នេសាទនិងទូក កាណូតរបស់អ្នកខាងក្នុងសហគមន៍នេសាទតែមិនមែនជាសមាជិក

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | ចំនួនគ្រួសារ | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | ឈិបរុញដោយដៃ | គ្រឿង | ៥ម ទៅ៦ម | ១០ | ពេញមួយឆ្នាំ |
| ២ | វាវគ្រែងឈាម ងាវភក់ និងលូកក្តាម | នាក់ | – | ៣០ | ខែ ០៥ ដល់ ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៥០ | ៧០-១០០ | |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | ចំនួនគ្រួសារ |
|---|---|---|---|---|
| ១ | មងត្រី | ម៉ែត្រ | ១គ្រួសារ=៥០០-៦០០ម | ៥០ |
| ៣ | លបក្តាម | លប | ១គ្រួសារ=៥០-១៥០លប | ១៥ |
| ៤ | ឈិបរុញដោយដៃ | គ្រឿង | ៥ម ទៅ៦ម | ៥៥ |

| ប្រភេទទូកកាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន | ២៥០ | ១០០០ | |
| ទូកចែវ | ២៨០ | | |

### ៤.គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ១១៥ | ១៣៨ | ២៥៣ |
| បង្គា | ៩៨ | ១២៥ | ២២៣ |
| ក្តាម | ៨៧ | ១១០ | ១៩៧ |
| មឹក ខ្យង និងក្រែងឈាម | ៧៥ | ៩២ | ១៦៧ |
| សរុប | ៣៧៥ | ៤៦៥ | ៨៤០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទអូរក្រសារមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ក្នុងរដូវទឹកជោរនិងព្រៃកោងកាងនិងការគ្រប់គ្រងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងជានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះ
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

**គោលបំណង**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍អូរក្រសារគឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទនិងរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រី | ម៉ែត្រ | ១គ្រួសារ=៣-៤ដៃ ១ដៃ=៥០ម | ខែ ០៥ ដល់ ខែ ១២ |
| ២ | មងក្តាម | ម៉ែត្រ | ១គ្រួសារ=១០០០ម | ពេញមួយឆ្នាំ |
| ៣ | លបក្តាម | លប | ០,២មx០,៤មx១,៥ម | ពេញមួយឆ្នាំ |
| ៤ | ឈិបរុញដោយដៃ | គ្រឿង | ៥ម ទៅ៦ម | ពេញមួយឆ្នាំ |
| ៥ | សន្ទូចរនង | ផ្លែ | ១០០/គ្រួសារ | ខែ ០៥ ដល់ ខែ ១២ |
| ៦ | រាវគ្រែមងឈាម ងាវ ភក់ និងលូកក្តាម | នាក់ | | ខែ ០៥ ដល់ ខែ ១២ |

ទីតាំង ឬកន្លែងនេសាទ

| ល.រ | ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | |
|---|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង | ចំនួនគ្រួសារ |
| ១ | ព្រែកអូរក្រសារ | ពេញមួយឆ្នាំ | មងត្រីឆ្កង ក្តាម បង្គាត្រីកាម៉ុង | ៩០ម-១៥០ម | ៥៧ |
| ២ | ព្រែកក្តប | ពេញមួយឆ្នាំ | មងក្បក លបតាម | ៩០ម-១៥០ម | ៤៥ |
| ៣ | ដែននេសាទផ្សេងទៀតក្រៅពីតំបន់អភិរក្ស | ពេញមួយឆ្នាំ | មងបង្គា ត្រីក្បកនិង លបក្តាម | ៩០ម-១៥០ម | ៥៤៣ |

ការប្រើប្រាស់ឧបករណ៍នេសាទគឺ ស្របតាមប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលេខ ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ខែមិថុនា ឆ្នាំ២០១៥

### គ.២. ផែនការចុះល្បាត

ជាទូទៅ ការចុះល្បាតជាភារកិច្ចរបស់គណៈកម្មការនិងសមាជិកសហគមន៍ ប៉ុន្តែការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមកការចុះល្បាតលើកន្លែងនេសាទសហគមន៍បានអនុវត្តតិចតួច ពីព្រោះថា ខ្វះមធ្យោបាយល្បាត ដូចនេះ សហគមន៍នេសាទអូរក្រសារបានគ្រោងរៀបចំផែនការល្បាតក្នុងគោលបំណង៖

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់

- សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម៖

| លរ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ២០០.០០០ (២ដង/ឆ្នាំ) | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០១៩ | ២០១៩ |
| ២ | រៀបចំមធ្យោបាយនិងសម្ភារៈ<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយឹត | ២.០០០.០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធអង្គការដៃគូ | ២០១៩ | ២០១៩ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ១០០.០០០ | ជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ពន្ធ័ | ២០១៩ | ២០១៩ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ជលផលនិងជំនាញពាក់ព័ន្ធ | ៥.០០០.០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០១៩ | ២០២២ |

គ.៣.ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេសនិងថវិកាប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជនិងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការនិងសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាននិងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្ដាលបានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទអូរក្រសារមានសភាពប្រែប្រួលខ្លះដែលបណ្ដាលមកពីកត្តាមនុស្សនិងធម្មជាតិ។

ផែនការកែលំអដែននេសាទក្នុងគោលបំណង៖

- បង្កើនជលត្រី និងវារីសត្វគ្រប់ប្រភេទនិងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ
- ធ្វើឱ្យសំបូរព្រៃកោងកាងឱ្យនៅក្នុងដែននេសាទសហគមន៍
- ទាក់ទាញភ្ញៀវទេសចរណ៍

ផែនការកែលំអដែននេសាទនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះដែននេសាទ | ទំហំ (ហត) | ទំហំដែលត្រូវកែលំអរ(ហត) | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ១ | ព្រែកអូរក្រសារ | ០៥ | ៣ | ស្ដារឡើងវិញ | ២០១៩ | ២០២២ |
| ២ | ព្រែកក្អប | ០៥ | ២ | ដាំកូនព្រៃកោងកាង | ២០១៩ | ២០២២ |

គ.៤.ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទអូរក្រសារ បានសម្រេចបង្កើតកន្លែងអភិរក្សចំនួន០២កន្លែង ដែលមានទំហំប្រហែល៩៦,៤១ ហិកតា ក្នុងនោះមានកន្លែងអភិរក្សកូនក្ដាមថ្មមានទំហំប្រហែល៥០ហិកតា និងតំបន់អភិរក្សព្រៃកោងកាងមានទំហំប្រហែល៤៦,៤១ហិកតា។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទអូរក្រសារ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សនេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃកោងកាង ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្ដល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ថែរក្សា និងការពារធនធានធម្មជាតិ
- ពិសេស ធនធានជលផល បរិស្ថាននិងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការនិងសមាជិកសហគមន៍នេសាទនេះបានបញ្ជាក់ថា សហគមន៍នេសាទអូរក្រសារបានសម្រេចបង្កើតកន្លែងអភិរក្សយ៉ាងតឹងរឹងដែលពុំអនុញ្ញាតិទុកនេសាទ ឬកាណូតធ្វើការឆ្លងកាត់ក្នុងកន្លែងអភិរក្សទាំងនេះ គឺកន្លែងអភិរក្សកូនក្ដាមថ្មដែលមានទំហំ៥០ហិកតា ជាកន្លែងសំខាន់បំផុត សម្រាប់ធ្វើការអភិរក្សធនធានជលផលដែលសមាជិសហគមន៍នេសាទមានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផលនិងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ដូចនេះសហគមន៍នេសាទអូរក្រសារបានសម្រេចបង្កើតកន្លែងអភិរក្សដូចបានបញ្ជាក់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហត | ការអភិរក្ស | កំណត់សំគាល់ |
|---|---|---|---|---|
| ១ | កន្លែងអភិរក្សកូនក្ដាមថ្ម | ៥០ | ការអភិរក្សធនធានជលផល | |
| សរុបទំហំគិតជាហិកតា | | ៥០ | | |

កន្លែងអភិរក្សធនធានជលផលនិងព្រៃកោងកាង ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គោលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្ដាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងៗសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយនិងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| កន្លែងអភិរក្សកូនក្ដាមថ្ម | ៥០ | • ប្រភេទត្រីសំខាន់<br>• ប្រភេទក្ដាមថ្ម<br>• ប្រភេទសារាយ<br>• ប្រភេទពពួកល្មូន | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលស៊ីម៉ង់ ៦ ដើម<br>• ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៩ | ២០២២ |

គ.៥.ផែនការគ្រប់គ្រងព្រៃកោងកាង

តំបន់ព្រៃកោងកាង បានគ្របដណ្តប់លើដែននេសាទសហគមន៍អូរក្រសាដែលមានទំហំប្រហែល៤៦,៤១ ហិកតា ដោយបានផ្តល់នូវសក្តានុពលនិងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រីសត្វល្អូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀត សម្រាប់ជាជម្រករស់នៅបង្កកំណើតជាកូននិងជាចំណីផងដែរ។ ដូចនេះផែនការគ្រប់គ្រងព្រៃកោងកាង ក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃកោងកាងឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី វារីសត្វគ្រប់ប្រភេទ ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឱ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការនិងសមាជិកសហគមន៍នេសាទអូរក្រសាបានកំណត់ បែងចែកព្រៃកោងកាង កន្លែងអភិរក្សនិងកន្លែងប្រើប្រាស់ព្រៃកោងកាងដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ កន្លែងប្រើប្រាស់ព្រៃកោងកាងត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឱ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។

ខាងក្រោមនេះជាផែនការគ្រប់គ្រងព្រៃកោងកាងក្នុងសហគមន៍អូរក្រសាមានដូចជា៖

| ឈ្មោះ/ទីតាំង | ទំហំ ហត | ប្រភេទកូនឈើ ដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ថែរក្សា និង ការពារ ព្រៃកោងកាង | ៤៦,៤១ | ព្រៃកោងកាង | • ផ្សព្វផ្សាយផែនការគ្រប់គ្រងព្រៃកោងកាង<br>• បោះបង្គោល<br>• ដាក់ស្លាកសញ្ញាការពារ<br>ត្រួតពិនិត្យ និងការពារ<br>• | ២០១៩ | ២០២២ |

គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសលេខ៣២៥ប្រក កសក ស្តីពីការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្កោរដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូចនេះផងដែរ សហគមន៍នេសាទអូរក្រសាបានផ្តោតសំខាន់លើការចិញ្ចឹមត្រីមានដូចជា ការចិញ្ចឹមត្រីទឹកសាប ការចិញ្ចឹមត្រីឆ្កុងនិងក្តាមថ្ម ពីព្រោះសហគមន៍នេះស្ថិតជាប់នឹងសមុទ្រ។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទអូរក្រសាក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការនិងសមាជិកសហគមន៍នេសាអូរក្រសាបានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រី (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីឆ្តោងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបេ ចំនួន ២០គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបេចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ២០ បេ ទំហំ ៥ម x៣ម x២,៥ម ត្រីឆ្តោង | កូនត្រីឆ្តោង | ៥០០ /គ្រួសារ | ២០១៩ | ២០២២ |
| ចិញ្ចឹមក្តាមថ្ម តាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន ៦ គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន<br>• តាមដានត្រួតពិនិត្យ | ទំហំដី១០ អា/គ្រួសារ | កូនក្តាមថ្ម | ៩០០កូន/គ្រួសារ | ២០២១ | ២០២២ |

**គ.៧. ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទអូរក្រសារបានគ្រោងផែនការរៀបចំកន្លែងកំសាន្តនៅកន្លែងមាត់សមុទ្រដែលជាដែននេសាទរបស់សហគមន៍នេសាទដែលអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯងសម្រាប់ក្នុងការចូលរួមចំណែកក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ក្នុងគោលបំណង៖

- បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ
- ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទមានដូចជា៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភពថវិកា | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| រៀបចំកន្លែងកំសាន្តសម្រាប់សហគមន៍នេសាទអូរក្រសារ | • ផ្សព្វផ្សាយទស្សនៈដល់សមាជិកសហគមន៍<br>• ការរៀបចំក្រុមសម្រាប់អនុវត្ត<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• បណ្តុះបណ្តាលពីការរៀបចំឯកសារ<br>• ត្រួតពិនិត្យតាមដាន | គាំទ្រដោយដៃគូរអភិវឌ្ឍ | ២០១៩ | ២០២២ |

**គ.៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ**

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទត្រូវបានបញ្ជាក់ពីគុណភាពនិងចំណេះដឹងដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការបានប្រើនិតិវិធីស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួង

កសិកម្មវុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវនិងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទ គឺថ្មីដែលសមត្ថភាពរបស់សមាជិកគណៈកម្មការមានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួលទំនាក់ទំនងជាមួយដៃគូរអភិវឌ្ឍន៍ និងការរៀបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ ដូចនេះផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ នឹងត្រូវបានរៀបចំក្នុងគោលបំណង៖

- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ
- យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់
- បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយសហគមន៍និងអ្នកពាក់ព័ន្ធ

ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទមានដូចជា៖

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិត រដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០១៩ | ២០១៩ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០២០ | ២០២០ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០២១ | ២០២១ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០២១ | ២០២១ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០២២ | ២០២២ |

គ.៩. ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ

ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគតនិងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់និងចូលរួមចំណែកក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការសកម្មភាពមានដូចខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត ២០១៩-២០២២ | | | តម្លៃប៉ាន់ស្មាន (គិតជារៀល ) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | |
| ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | ខណ្ឌរដ្ឋបាលជលផល | ៤ | ៤ | ៤ | ២.០០០.០០០ | រដ្ឋបាលជលផល ដៃគូរអភិវឌ្ឍន៍សង្កាត់ |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ស.ន | ៤ | ៤ | ៤ | ៧៥០.០០០ | រដ្ឋបាលជលផល ដៃគូរអភិវឌ្ឍន៍សង្កាត់ |

គ.១០.ផែនការបង្កើតស្នាក់ការនិងបណ្ណាល័យសហគមន៍នេសាទ

ពេលបច្ចុប្បន្ន សហគមន៍នេសាទអូរក្រសារពុំទាន់មានស្នាក់ការនៅឡើយ ហើយគណៈកម្មការមានការលំបាកក្នុងពេលបំពេញការងារក៏ដូចជា ការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូច្នេះ ស្នាក់ការនិងបណ្ណាល័យ គួរត្រូវបានបង្កើតឡើងនិងបំពាក់សម្ភារៈមួយចំនួនដូចជា តុ កៅអី និងទូឯកសារ។ គម្រោងស្នាក់ការនិងបណ្ណាល័យមានដូចខាងក្រោម៖

| សកម្មភាព | ទីតាំងគម្រោង | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | តម្លៃប៉ាន់ ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|---|
| គម្រោងស្នាក់ការ | ស.ន | ១/១/១៩ | ១/៦/១៩ | ១៥.០០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន |
| គម្រោងបណ្ណាល័យ | ស.ន | ១/២/២២ | ១/១២/២២ | ៧.៨០០.០០០ | |
| សរុប | | | | ២២.៨០០.០០ | |

គ.១១.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍នេសាទអូរក្រសារ ត្រូវដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូរអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាសង្កាត់ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។

ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រទ្រង់សហគមន៍នេះមានក្នុងតារាងខាងក្រោម៖

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូល (រៀល) |
|---|---|---|---|---|
| វិភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយ និងបណ្ណវិភាគទាន | ខែ៦ ឆ្នាំ២០១៩ | ខែ៦ឆ្នាំ២០២២ | ១.៣៣៧.៥០០ |
| ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណ វិភាគទាន | ខែ៦ ឆ្នាំ២០១៩ | ខែ៦ឆ្នាំ២០២២ | ៨.២៥០.០០០ |
| សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុតរបរ<br>• ជាថវិកាផ្ទាល់ | ខែ៦ ឆ្នាំ២០១៩ | ខែ៦ឆ្នាំ២០២២ | ៤.០០០.០០០ |
| ក្រុមប្រឹក្សាសង្កាត់ | ការពារធនធានធម្មជាតិ | ខែ៦ឆ្នាំ២០១៩ | ខែ៦ឆ្នាំ២០២២ | ៧៥០.០០០ |

ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទអូរក្រសារ ត្រូវរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្ត្រទាំងមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ ចំពោះផែនការណាដែលទាក់ទង នឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃ

កោងកាង កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- គៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ/
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូរក្រសាររយៈពេល ០៣ ឆ្នាំ (ខែមិថុនា ឆ្នាំ២០១៩- ខែមិថុនា ឆ្នាំ ២០២២)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការប្រើប្រាស់ឧបណ៍នេសាទ | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | ១.៥០០.០០០ | | ២០១៩ | ២០២២ |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/២ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ១.៥០០.០០០ | អង្គការដៃគូរសប្បុរសជនរដ្ឋាភិបាល | | |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ពន្ធ នឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការនិងសមាជិកចូលរួមឃ្លាំមើលនិងរាយការណ៍ | | | | |
| ២.ផែនការចុះល្បាត | •ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>•សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍<br>•គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | ៧,៣០០,០០០ | | | |
| ២.១.ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ផែនការល្បាតបានពិគ្រោះយោបល់និងរៀបចំសម្រាប់អនុវត្ត | ២០០.០០០ | | | |
| ២.២.រៀបចំមធ្យោបាយនិងសម្ភារៈ | មធ្យោបាយនិងសម្ភារៈបានគ្រោងនិងរៀបចំ | ២.០០០.០០០ | | | |
| ២.៣.ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ផែនការល្បាតត្រូវបានផ្សព្វផ្សាយ | ១០០.០០០ | | | |
| ២.៤.អនុវត្តផែនការចុះល្បាត | ផែនការចុះល្បាតត្រូវបានចុះអនុវត្ត | ៥.០០០.០០០ | | | |
| ៣.ផែនការកែលំអផែននេសាទ | • បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទនិងព្រៃកោងកាង<br>• ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ<br>• មានភ្ញៀវទេសចរណ៍និងផ្តល់ការងារដល់សហគមន៍<br>• សហគមន៍មានដើមទុនសម្រាប់ខ្លួនឯង | ២១.០០០.០០០ | | | |
| ២.១.ផែនការស្តារព្រែកអូរក្រសារដែលមានប្រវែង ៣ ហិកតា | •ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់<br>•ធ្វើការសិក្សាលើទំហំដែលត្រូវស្តារនិង<br>•ការស្តារព្រែកអូរក្រសារ | ២០.០០០.០០០ | អង្គការដៃគូរសប្បុរសជនរដ្ឋាភិបាល | ២០១៩ | ២០១២២ |
| ២.១.ផែនការដាំព្រៃកោងកាងនៅព្រែកខ្ពបដែលមានទំហំផ្ទៃដី២ហិកតា | រៀបចំថ្នាលកូនឈើ ពីធីដាំកូនឈើនិងដាក់ស្លាកសញ្ញាការពារ ថែរក្សា ការពារ | ១.០០០.០០០ | | ២០១៩ | ២០១២២ |

| | | | | | |
|---|---|---|---|---|---|
| ៤.ផែនការរៀបចំកន្លែងអភិរក្ស | •ប្រភេទត្រីមេពូជនិងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃកោងកាងនឹងត្រូវបានការពារ<br>•ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្សនឹងចូលរួមថែរក្សា | ៩.២៨០.០០០ | | ២០១៩ | ២០១២២ |
| ៤.១.បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្សកូនក្លាមថ្មទំហំ ៥០ហិកតា | ចំនួន១២បង្គោលនឹងបានបោះនៅកន្លែងអភិរក្សទាំងពីរដោយមានផែនទីសំគាល់កន្លែងអភិរក្ស | ៥.០០០.០០០ | | | |
| ៤.២ ផ្សព្វផ្សាយដល់ប្រជាជន | ប្រជាជននឹងយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ២០០.០០០ | អង្គការដៃគូ<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០១៩ | ២០២២ |
| ៤.៣ ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | ចំនួន០១ស្លាក ផ្ទាំងប៉ាណូនឹងបោះសម្រាប់ផ្សព្វផ្សាយ | ១.២០០.០០០ | | | |
| ៤.៤ សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ៤មX៥ម | ១.៨០០.០០០ | | | |
| ៤.៥ ចុះល្បាតជាប្រចាំ | បទល្មើសនេសាទនឹងថយចុះតាមរយៈការចុះល្បាត | ១.០៨០.០០០ | | | |
| ៥.ការគ្រប់គ្រងព្រៃកោងកាងសហគមន៍នេសាទ ៤៦,៤១ ហិកតា | • សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃកោងកាង<br>• ព្រៃកោងកាងត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | ២.០០០.០០០ | | | |
| ៥.១ ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃកោងកាង | សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃកោងកាង | ២០០.០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៩ | ២០២២ |
| ៥.២.ថែរក្សា និងការពារព្រៃកោងកាង | ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់និងដាក់ស្លាកសញ្ញាការពារ | ៨០០.០០០ | | | |
| ៥.៣ ចុះល្បាតជាប្រចាំ | សកម្មភាពកាប់បង្ហាញព្រៃកោងកាងនឹងត្រូវបានទប់ស្កាត់ | ១.០០០.០០០ | | | |
| ៦.ការអភិវឌ្ឍន៍វារីវប្បកម្ម | • បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>• រកប្រាក់ចំណូលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត។ | ១០.០០០.០០០ | | | |
| ៦.១.ចិញ្ចឹមត្រីឆ្តុងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែ ចំនួន ២០គ្រួសារ | | ៣.០០០.០០០ | ដៃគូអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០១៩ | ២០២២ |
| ៦.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន២០គ្រួសារត្រូវបានជ្រើសរើស | | | | |
| ៦.១.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | ចំនួន២០គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | | | | |
| ៦.១.៣ ធ្វើបែចិញ្ចឹមត្រីឆ្តុង | ចំនួន២០បែ ដែលក្នុង១បែមានទំហំ៥មX៣មX២,៥ម ត្រូវបានសាងសង់ | | | | |
| ៦.១.៤ ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី៥០០ កូននឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៦.១.៥ គ្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន២០គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| ៦.២.ចិញ្ចឹមក្តាមថ្មតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន៦គ្រួសារ | | | | | |
| ៦.២.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន៦គ្រួសារត្រូវបានជ្រើសរើស | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.២.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន៦គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីតក់កែ | | | | |
| ៦.២.៣ ធ្វើទីកន្លែងចិញ្ចឹម | ចំនួន៦គ្រួសារ ដែលក្នុង១គ្រួសារមានទំហំដី១០អាត្រូវបានរៀបចំ | ៧.០០០.០០០ | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០១៩ | ២០២២ |
| ៦.២.៤ ការដាក់កូន | ចំនួនកូនត្រី៩០០កូននឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៦.២.៥ ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន៦គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៧.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍** | • បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិតនិង<br>• ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួន | **១១.៣៦០.០០០** | | | |
| ៧.១.ផ្សព្វផ្សាយទស្សនៈដល់សមាជិកសហគមន៍ | ទស្សនៈទាននឹងផ្សព្វផ្សាយដល់សមាជិកសហគមន៍ | | | | |
| ៧.២.បង្កើតក្រុមសម្រាប់អនុវត្ត | ក្រុមរៀបចំកន្លែងកំសាន្តសហគមន៍នឹងត្រូវបានបង្កើត | | | | |
| ៧.៣.រៀបចំគោលការណ៍និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនឹងត្រូវបានរៀបចំ | ១១.៣៦០.០០០ | ដៃគូរអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០១៩ | ២០២២ |
| ៧.៤.បណ្តុះបណ្តាលពីការរៀបចំឯកសារនិងថវិកា | ឯកសារ ថវិកានឹងបានបណ្តុះបណ្តាល | | | | |
| ៧.៥.ត្រួតពិនិត្យតាមដាន | ក្រុមរៀបចំកន្លែងកំសាន្តនឹងធ្វើការត្រួតពិនិត្យនិងកែលម្អ | | | | |
| **៨.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | • គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>• យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់និង<br>• បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | **១.៣០០.០០០** | | | |
| ៨.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍និងលិខិតរដ្ឋបាលនឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០១៩ | ២០១៩ |
| ៨.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកានឹងត្រូវបានបណ្តុះបណ្តាល | ៣០០.០០០ | រដ្ឋាភិបាល អង្គការដៃគូរ សប្បុរសជន | ២០២០ | ២០២០ |
| ៨.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២១ | ២០២១ |
| ៨.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០.០០០ | | ២០២១ | ២០២១ |
| ៨.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២២ | ២០២២ |
| **៩.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | **២.៧៥០.០០០** | | | |
| ៩.១.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | សមាជិកសហគមន៍នឹងផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋាន | ២.០០០.០០០ | រដ្ឋាភិបាល អង្គការដៃគូរ សប្បុរសជន | ២០១៩ | ២០២២ |
| ៩.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | សមាជិកសហគមន៍នឹងត្រូវបានផ្សព្វផ្សាយលក្ខន្តិកៈនិងបបញ្ជាផ្ទៃក្នុង | ៧៥០.០០០ | | | |
| **១០.ផែនការបង្កើតស្នាក់ការសហគមន៍នេសាទ** | | **២២.៨០០.០០០** | | | |
| ១០.១.បង្កើតស្នាក់ការ | ស្នាក់ការរបស់សហគមន៍នឹងត្រូវបានជួសជុល | | | | |
| ១០.២.បំពាក់សម្ភារៈ | សម្ភារៈកៅអីនិងទូឯកសានឹងត្រូវបានបំពាក់ | ១៥.០០០.០០០ | រដ្ឋាភិបាល អង្គការដៃគូរ | ២០១៩ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| ១០.៣.គម្រោងសាងសង់បណ្ណាល័យ | បណ្ណាល័យនឹងត្រូវបានសាងសង់ | ៧.៨០០.០០០ | សប្បុរសជន | | |
| ១១. ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ | | ១៤.៣៣៧.៥០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៩ | ២០២២ |
| ១១.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ១.៣៣៧.៥០០ | | | |
| ១១.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៨.២៥០.០០០ | | | |
| ១១.៣. អំណោយពីសប្បុរសជននិងអង្គការដៃគូ | សប្បុរសជននិងអង្គការដៃគូអភិវឌ្ឍន៍ | ៤.០០០.០០០ | | | |
| ១១.៤.ក្រុមប្រឹក្សាសង្កាត់ | មូលនិធិរបស់សង្កាត់ | ៧៥០.០០០ | | | |

# តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទអូរក្រសារក្នុងរយៈពេល ០៣ ឆ្នាំ

| សកម្មភាព | ២០១៩ | | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | |
| | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.ផែនការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.ផែនការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.ផែនការគ្រប់គ្រងព្រៃកោងកាង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១១.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកែប
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែ.......ឆ្នាំកុរ.ឯកស័កព.ស.២៥៦៣
ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩

**នាយផ្នែករដ្ឋបាលជលផលដំណាក់ស្តេច**

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផល
ដំណាក់ស្តេច
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ ខែ ឆ្នាំកុរ.ឯកស័កព.ស.២៥៦៣
ថ្ងៃទី..........ខែ............ឆ្នាំ២០១៩

**នាយសង្កាត់រដ្ឋបាលជលផលអូរក្រសា**

លេខ:.......
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផល
អូរក្រសា
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែ.......ឆ្នាំកុរ.ឯកស័កព.ស.២៥៦៣
ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩

**មេចៅសង្កាត់**

សូមគោរពជូន
លោកចៅសង្កាត់អូរក្រសា
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែ.......ឆ្នាំកុរ.ឯកស័ក ព.ស.២៥៦៣
.......ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩

**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**អូរក្រសា**

លេខ.......
បានឃើញ និងឯកភាព
ថ្ងៃ.......ខែ.......ឆ្នាំកុរ.ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ,ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

លេខ.......
បានឃើញ និង គោរពជូន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
ថ្ងៃ.......ខែ.......ឆ្នាំកុរ.ឯកស័ក ព.ស. ២៥៦៣
.......ថ្ងៃទី .......ខែ.......ឆ្នាំ ២០១៩

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកែប**

លេខ:.......
បានឃើញ និង គោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តកែប
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែ.......ឆ្នាំកុរ.ឯកស័ក ព.ស. ២៥៦៣
.......ថ្ងៃទី.......ខែ.......ឆ្នាំ ២០១៩

**នាយខណ្ឌរដ្ឋបាលជលផលកែប**